**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ......................សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ............ ឆ្នាំ២០១១

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកា: (១) - ចំនួន ១.៦៤៤.៤៣៩,៨៨ ដុល្លារអាមេរិក សម្រាប់ការងារជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធប្រឡាយមេសន្លុង (ដំណាក់កាលទី ២) និង (២) -ចំនួន ៦៤៨.១៩៨,៨២ ដុល្លារអាមេរិក សម្រាប់ការងារជួសជុលនិងស្តារឡើងវិញនូវប្រព័ន្ធប្រឡាយមេនិងទំនប់ដងជីនីជ ស្ថិតក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

**យោង:** លិខិតលេខ ១២៩៧ ធទឧ ចុះថ្ងៃទី២២ ខែមិថុនា និងលេខ១៨៨៧ ធទឧ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យលើសំណើរបស់ក្រសួងធនធានទឹក និងឧតុនិយម និងសូមឯកភាពជាគោលការណ៍ផ្តល់ថវិកាដូចខាងក្រោម:

១- ផ្តល់ថវិកាចំនួន ៤៥.០០០,០០ ដុល្លារអាមេរិក (សែសិបប្រាំពាន់ដុល្លារអាមេរិក) ដើម្បីធ្វើការចរចាជាមួយក្រុមហ៊ុនមានស្រាប់ដែលកំពុងអនុវត្តកិច្ចសន្យាជួសជុល និងស្តារឡើងវិញនូវប្រឡាយមេប៉ាន់ណោ ស្ថិតក្នុងឃុំជ័យធំ និងឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងធ្វើវិសោធនកម្មកិច្ចសន្យានេះ សម្រាប់ការងារជួសជុល និងស្តារឡើងវិញប្រឡាយមេសន្លុងប្រវែង ៣០០ម៉ែត្រ ពីបឹងសំបូរមកស្ថានីយ៍បូមទឹក សម្តេច **ហ៊ុន សែន** ទី៤៤ ។

២- ថវិកាចំនួន ៧០០.០០០ ដុល្លារអាមេរិក (ប្រាំពីររយពាន់ដុល្លារអាមេរិក) សម្រាប់ការងារជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធប្រឡាយមេ និងទំនប់ដងជីនីជ (តាមសំណើនៃគំនូសប្លង់ និងរួមបញ្ចូលបន្ថែមការងារសាងសង់ស្ថានីយ៍បូមទឹកដោយបំពាក់ម៉ាស៊ីនបូមទឹកម៉ាក " **ហ៊ុន សែន** " ចំនួនពីរគ្រឿង ) ស្ថិតក្នុងភូមិព្រៃធំ ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

គម្រោងទាំងពីរខាងលើត្រូវប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 0132-CAM(SF)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u>
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តកណ្តាល
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្តាល
- ឯកសារ-កាលប្បវត្តិ